# បទឧទ្ទេសនាម
## របស់
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ដើម្បីពិភាក្សា និង អនុម័ត សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០

*រដ្ឋសភា, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩*

ខ្ញុំបាទសូមគោរព ៖

- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;
- ឯកឧត្តមបណ្ឌិតអនុប្រធានទី ១ នៃរដ្ឋសភា;
- លោកជំទាវកិត្តិសង្គហបណ្ឌិតអនុប្រធានទី ២ នៃរដ្ឋសភា;
- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា, នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ ដើម្បីពិនិត្យ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០** ចូលក្នុងរបៀបវារៈនៃសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភាក៏បានរាយការណ៍លម្អិតបន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះដែរ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង; ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ,

ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេសនាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ ។

## I- អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២០

សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០២០ នេះ មានគោលដៅគាំទ្រការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និង វិធានការកែទម្រង់ស៊ីជម្រៅ, មុតស្រួច, និងជាក់ស្តែងនានា, ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមាជូនប្រទេសជាតិ ដើម្បីឆ្លើយតបនឹងសំណូមពរ, សេចក្តីត្រូវការ, និងការរំពឹងទុករបស់ប្រជាជនកម្ពុជា, នៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍរបស់កម្ពុជា ក្នុងឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាប ឈានឆ្ពោះទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និង ប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ដូច**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** បានលើកឡើងមុននេះ ។ ក្នុងគោលដៅនេះ, រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា មានបេសកកម្មសំខាន់ៗជាច្រើន រួមមានជាអាទិ៍ ៖ (**ទី១**)-បន្តខិតខំរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ; (**ទី២**)-បង្កើតការងារប្រកបដោយគុណភាពសម្រាប់យុវជនផង និង ឆ្លើយតបបានប្រកបដោយប្រសិទ្ធភាពចំពោះក្តីរំពឹងទុករបស់ប្រជាជនដែលបន្តកើនឡើងជាលំដាប់; (**ទី៣**)-ផ្តល់សេវាសាធារណៈសំខាន់ៗប្រកបដោយគុណភាព ជាពិសេស ហេដ្ឋា-រចនាសម្ព័ន្ធរូបវន្ត, សេវាអប់រំ, សុខាភិបាល, យុត្តិធម៌ និង សេវាមូលដ្ឋានចាំបាច់ផ្សេងទៀត រួមទាំង របបសន្តិសុខសង្គម និង ការធានាសុវត្ថិភាពចំណូល ជាពិសេស សម្រាប់ប្រជាជនងាយរងគ្រោះ ។ល។; និង (**ទី៤**)-បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ច នៃស្ថាប័នរដ្ឋ, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃសេវាសាធារណៈ ។

ជាបរិការណ៍សកល, បញ្ហាភូមិសាស្ត្រនយោបាយ និង សណ្តាប់ធ្នាប់ថ្មីរបស់ពិភពលោកក្នុងទម្រង់ពហុប៉ូល កាន់តែវិវត្តន៍ស្មុគស្មាញ និង ស្រួចស្រាល់ជាងមុន ហើយការប្រជែងឥទ្ធិពល និង មនោគមន៍វិជ្ជារវាងលោកខាងលិច និង ខាងកើត ហាក់បីដូចជាបាននិងកំពុងនាំពិភពលោកឈានទៅរកសង្គ្រាមត្រជាក់សារជាថ្មីម្តងទៀត ។ ទន្ទឹមនេះ, សង្គ្រាមពាណិជ្ជកម្ម, ដែលបង្កប់ជាមួយនូវសង្គ្រាមបច្ចេកវិទ្យា, រវាងអាមេរិក និង ចិន ក៏បាននិងកំពុងធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ចសកល និង កំពុងបង្កភាពរអាក់រអួលដល់ខ្សែច្រវាក់នៃការផ្គត់ផ្គង់-សកលថែមទៀត ក្នុងខណៈដែលស្ថានភាពសេដ្ឋកិច្ចពិភពលោក និង តំបន់មួយចំនួន នៅបន្តផុយស្រួយ និង មានហានិភ័យនៃការថមថយកំណើនស្រាប់ ។ ស្ថានភាពទាំងនេះ អាចនឹង

នាំទៅដល់វិបត្តិសេដ្ឋកិច្ចពិភពលោកសារជាថ្មីម្តងទៀត នៅចុងឆ្នាំ ២០២០ ឬ ដើមឆ្នាំ ២០២១ ខាងមុខ ។ ពិតណាស់, កម្ពុជា, ដែលជាប្រទេសមានសេដ្ឋកិច្ចបើកចំហខ្លាំង ហើយក្បាល-ម៉ាស៊ីនអូសកំណើនសេដ្ឋកិច្ចក៏ពឹងផ្អែកច្រើនលើកត្តាខាងក្រៅ, អាចនឹងទទួលរងនូវឥទ្ធិពលអវិជ្ជមានពីហានិភ័យខាងក្រៅប្រទេសទាំងនេះ ដោយមិនទាន់គិតទៅដល់ផលប៉ះពាល់ដែលអាចបណ្តាលមកពីភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន ក៏ដូចជា ហានិភ័យខាងក្នុងប្រទេសមួយចំនួនទៀត ។

ដូចនេះ, កម្ពុជាចាំបាច់ត្រូវត្រៀមខ្លួន និង ពង្រឹងសមត្ថភាពផ្ទៃក្នុងឱ្យបានល្អ ដើម្បីទប់ទល់បញ្ហាប្រឈម និងហានិភ័យ, ទាំងខាងក្នុង និង ខាងក្រៅ, ព្រមទាំងត្រូវធ្វើការវះកាត់ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធពុំរ៉ែមួយចំនួន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងធ្វើពិពិធកម្មសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងក្លា និង ដើម្បីអាចឈរដោយខ្លួនឯង ។ កម្ពុជាត្រូវកសាងនូវប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ ឆ្លាតវៃ និង មានសមត្ថភាពខ្លាំងពូកែ ដើម្បីអាចគ្រប់គ្រង និង ដោះស្រាយបញ្ហាសង្គម និង សេដ្ឋកិច្ច ដែលកាន់តែធំ និង ស្មុគស្មាញជាងមុន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្នុងរយៈពេលវែង ។

ក្នុងន័យនេះ, **ថវិកាឆ្នាំ ២០២០ ត្រូវតែជាថវិកាយុទ្ធសាស្ត្រនៃការផ្តួបកម្លាំងសរុប ដើម្បីទប់ទល់នឹងបញ្ហាប្រឈម និង ហានិភ័យ, ទាំងក្នុង និង ក្រៅប្រទេស, តាមរយៈការពង្រឹងសមត្ថភាពផ្ទៃក្នុង ដោយជំរុញឱ្យបានខ្លាំងក្លានូវការកែទម្រង់ស៊ីជម្រៅ និង មុតស្រួច ដើម្បីធានាសុខសន្តិភាព ស្ថិរភាព និង ចីរភាពនៃកំណើនសេដ្ឋកិច្ច សំដៅលើកកម្ពស់សុខុមាលភាពជូនប្រជាជន លើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យឆ្នាំ ២០៣០ និង ឆ្នាំ ២០៥០ ។**

## II- អំពីអតិក្រម និង គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០២០

ឈរលើមូលដ្ឋានខាងលើនេះ, ថវិកាឆ្នាំ ២០២០ ត្រូវបានគិតគូរ និង រៀបចំឡើងក្នុងគោលដៅទ្រទ្រង់ដល់និរន្តរភាពនៃប្រតិបត្តិការរបស់រដ្ឋ, គាំទ្រចលនការនៃការកែទម្រង់, និងពង្រឹងប្រព័ន្ធផ្ទៃក្នុង ដើម្បីពង្រឹងភាពជាម្ចាស់ទៅថ្ងៃអនាគត និង ដើម្បីត្រៀមខ្លួនទប់ទល់ និង ផ្តល់ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះរាល់បញ្ហាប្រឈម និង ហានិភ័យ, ទាំងខាងក្នុង និង ខាងក្រៅប្រទេស, ពិសេសដើម្បីសម្រេចឱ្យបានជាអតិបរមានូវ **គោលដៅជាយុទ្ធសាស្ត្រទាំង ៤** ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤** ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព ក៏ដូចជាបន្តផ្តល់អាទិភាពលើ**វិស័យអាទិភាពទាំង ៤** គឺ៖ **មនុស្ស**, **ផ្លូវ**, **ភ្លើង**, និង **ទឹក** ព្រមទាំងកិច្ចការសំខាន់ៗមួយចំនួនទៀត ដែលឆ្លើយតបនឹងតម្រូវការអភិវឌ្ឍកម្ពុជានៅក្នុងដំណាក់កាលថ្មីនេះ ។

អាស្រ័យដោយ, **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** បានជម្រាបជូនអង្គសភារួចហើយ អំពីគោលដៅផ្នែកគោលនយោបាយនៃការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០ ខ្ញុំសូមមិនជម្រាបជូនឡើងវិញទេ, ប៉ុន្តែ ខ្ញុំសូមគូសបញ្ជាក់បន្ថែមថា ថវិកាឆ្នាំ ២០២០ ត្រូវបានរៀបចំឡើងដោយឈរលើ**អភិក្រម និង គោលការណ៍ ដូចតទៅ៖ (១)-គោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដូចបានកំណត់ ជាពិសេសការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវវិធានការគោលនយោបាយគន្លឹះដែលត្រូវបានដាក់ចេញ; (២)-ធានាចីរភាព និង សមិទ្ធកម្មនៃចំណូល; (៣)-ផ្សារភ្ជាប់ការប្រមូលចំណូល ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និង លទ្ធផលការងារជាមួយនឹងការវិភាជថវិកា; (៤)-ការកំណត់លំដាប់អាទិភាពសំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា; (៥)-ការយកចិត្តទុកដាក់លើមនុស្ស; (៦)-កំណត់តម្លៃជាក់ស្ដែងនៃកម្មវិធី/សកម្មភាព; (៧)-ការផ្ទេរថវិកាឱ្យដល់អង្គភាពដែលអនុវត្តការងារផ្ទាល់; (៨)-ការរក្សាតុល្យភាព និង ចីរភាពថវិកា; និង (៩)-ការបន្តពង្រឹងភាពប្រុងប្រយ័ត្នខ្ពស់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ។**

## III- អំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច

នៅក្នុងផ្នែកនេះ, អាស្រ័យដោយអត្ថបទពិស្ដារនៃសេចក្ដីថ្លែងហេតុ បានគូសរំលេចរួច-ហើយអំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២០, ក៏ដូចជាអំពីបញ្ហាប្រឈម និង ហានិភ័យ, ទាំងផ្នែកក្រៅប្រទេស, ទាំងផ្នែកក្នុងប្រទេស, ព្រមទាំងអំពីវិធានការគោលនយោបាយមុតស្រួចមួយចំនួនដែលត្រូវបានដាក់ចេញ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចីរភាព; ដូចនេះ ដើម្បីចំណេញពេល, ខ្ញុំបាទសូមជម្រាបជូនជាសង្ខេបថា តាមការព្យាករណ៍, កំណើនសេដ្ឋកិច្ចកម្ពុជានៅឆ្នាំ ២០២០ នឹងស្ថិតក្នុងរង្វង់ ៦,៥% ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ ១ ៨១៦ ដុល្លារអាមេរិក ធៀបនឹង ១ ៦៧៩ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៩ ។ ជារួម, ការព្យាករម៉ាក្រូសេដ្ឋកិច្ចមកទល់ពេលថ្មីៗនេះ បង្ហាញថា កម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ ក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ។ ប៉ុន្តែ, សេដ្ឋកិច្ចកម្ពុជាអាចជួបប្រទះនឹងបញ្ហាប្រឈម និង ហានិភ័យកាន់តែខ្ពស់, ទាំងទិដ្ឋភាពខាងក្នុង និង ខាងក្រៅប្រទេស, ដែលអាចនឹងប៉ះពាល់ដល់ចីរភាពនៃកំណើន និង និរន្តរភាពនៃការអភិវឌ្ឍប្រទេស ។ ដូចនេះ, ដើម្បីត្រៀមខ្លួនដោះស្រាយហានិភ័យចម្បងៗជាយថាហេតុ, រាជរដ្ឋាភិបាលបានគិតគូរជាយុទ្ធសាស្ត្រ ដោយឈរលើស្មារតីប្រុងប្រយ័ត្នខ្ពស់ និង ត្រៀមដាក់ចេញនូវវិធានការគោលនយោបាយផ្សំចម្រុះមួយចំនួន ដូចមានលម្អិតនៅក្នុងសេចក្ដី-ថ្លែងហេតុនៃសេចក្ដីព្រាងច្បាប់នេះ ដោយផ្ដោតលើវិធានការធំៗចំនួន ៤ គឺ៖

(១)-ស្រូបយកការប៉ះទង្គិចដែលអាចកើតមានឡើងនៅក្នុងយថាហេតុអាក្រក់ណាមួយ;

(២)-ដោះស្រាយបញ្ហាជារចនាសម្ព័ន្ធដែលដាក់កម្រិតលើភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច-ជាតិ;

(៣)-ពង្រឹងភាពធន់នឹងវិបត្តិលើផ្នែកម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ; និង

(៤)-បង្កើនប្រសិទ្ធភាព និង ស័ក្តិសិទ្ធិភាពនៃស្ថាប័នសាធារណៈ ។

## IV- អំពីក្របខ័ណ្ឌថវិកាឆ្នាំ ២០២០

ក្របខណ្ឌថវិកាឆ្នាំ ២០២០ ត្រូវបានកំណត់ដូចតទៅ៖

១-ចំណូលក្នុងប្រទេសថវិការដ្ឋ ឬ ចំណូលក្នុងប្រទេសថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ ២៦,៣ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៦,៥ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ២២,១៣% នៃ ផសស និង មានកំណើន ២៤,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ។ ក្របខណ្ឌថវិកាឆ្នាំ ២០២០ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង ២១,៩៦% នៃ ផសស ដែលមានកំណើនចំនួន ២,៦៣ ពិន្ទុភាគរយនៃ ផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៩ ពោលគឺនឹងសម្រេចបានលើស **គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ** ដែលត្រូវបានកំណត់ឱ្យកើនជាមធ្យម ០,៣ ពិន្ទុភាគរយនៃ ផសស ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ ។

២-ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួនប្រមាណ ៣៣,៣ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៨,២ ប៊ីលានដុល្លារអាមេរិក, ស្មើនឹង ២៨,០១% នៃ ផសស និង មានកំណើន ២២,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩; ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន ១៩,៨ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៤,៩ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ១៦,៦៥% នៃ ផសស, និង មានកំណើន១០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ។ ត្រង់នេះ, ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា គម្រោង **ចំណាយបន្ទុកបុគ្គលិកសរុបនៃថវិការដ្ឋ** ឆ្នាំ ២០២០ នឹងមានទំហំប្រមាណ ៩,១ ទ្រីលានរៀល, សមមូលនឹងប្រមាណ ២,២ ប៊ីលានដុល្លារអាមេរិក, ត្រូវជា **៧,៦៨% នៃ ផសស,** ឬ ស្មើនឹង **៤៦,១១%** នៃចំណាយចរន្តថវិការដ្ឋ ។ ទំហំចំណាយបន្ទុកបុគ្គលិកនេះឃើញថយចុះ ដោយសារការផ្ទេរការកត់ត្រាប្រាក់សោធននិវត្ត ចូលជាប្រភេទអត្ថប្រយោជន៍សង្គមនៃចំណាយមិនមែនបន្ទុកបុគ្គលិក ឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ ។ ប៉ុន្តែ, បើគិតបញ្ចូលប្រាក់សោធននិវត្តន៍ចំនួនប្រមាណ ១ ទ្រីលានរៀល, ដែលសមមូលនឹងប្រមាណ ២៤៨ លានដុល្លារអាមេរិក, នោះចំណាយបន្ទុកបុគ្គលិកនឹងឡើងដល់ ៨,៥២% នៃ ផសស ឬ ស្មើនឹង ៥១,១៨% នៃចំណាយចរន្តថវិការដ្ឋ ។ ការកើនឡើងចំណាយបន្ទុកបុគ្គលិកនេះ បានឆ្លុះបញ្ចាំងអំពីការផ្តល់អាទិភាពលើមនុស្សនៃគោលនយោបាយថវិការបស់រាជរដ្ឋាភិបាល ។

## V- អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០២០ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យមានទំហំស្មើនឹងប្រមាណ ២៤,១ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៥,៩ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ២០,២៤% នៃ ផសស, គឺមានកំណើន ២១,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ។ ក្នុងក្របខ័ណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយ អំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងអំពីគោលដៅចំណូលមូលធន, ទាំងចំណូលមូលធនក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស ។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលាខ្លះ, ខ្ញុំបាទសូមការអនុញ្ញាតមិនអធិប្បាយនូវចំណុចទាំងអស់នេះសាជាថ្មីឡើងវិញទេ ដោយគ្រាន់តែស្នើសុំគូសរំលេចបន្ថែមថា ដើម្បីរួមចំណែកសម្រេចគោលដៅចំណូលសារពើពន្ធដែលបានដាក់ចេញមកនេះ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, និង អគ្គនាយកដ្ឋានពន្ធដារ, ដែលជាអង្គភាពប្រមូលចំណូលធំពីរ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផ្ទាល់, ត្រូវខិតខំសម្រេចឱ្យបានតាមគោលដៅដែលត្រូវបានគ្រោង ដូចខាងក្រោម៖

- ចំណូលគយ និង រដ្ឋាករ ត្រូវបានគ្រោងប្រមាណ ១១,៦ ទ្រីលានរៀល, សមមូលនឹងប្រមាណ ២,៩ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ៩,៧៨% នៃ ផសស គឺមានកំណើន ២៨,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩;
- ចំណូលពន្ធដារ ត្រូវបានគ្រោងប្រមាណ ៩,៤ ទ្រីលានរៀល, សមមូលនឹងប្រមាណ ២,៣ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ៧,៩៣% នៃ ផសស គឺមានកំណើន ២១,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ក្នុងពេលដែលនៅឆ្នាំ ២០២០ រាជរដ្ឋាភិបាលមិនបានដាក់ចេញនូវប្រភេទពន្ធថ្មី ឬ បង្កើនអត្រាពន្ធនោះទេ ។

### ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

#### ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

ក-១- <u>អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ</u>

ដូចបានគូសបញ្ជាក់នៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ, ហើយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប បានជម្រាបជូនអំបាញ់មិញហើយដែរ,** ប៉ុន្តែខ្ញុំសូមគូសបញ្ជាក់បន្ថែមថា ថវិកាថ្នាក់ជាតិឆ្នាំ ២០២០ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិត ប្រមាណ ១៨ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៤,៤ ប៊ីលានដុល្លារអាមេរិក, ត្រូវជា ១៥,១៥% នៃ ផសស, មានកំណើន ៧,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ដែលក្នុងនោះ ៖

ក.១.១-<u>ចំណាយលើបន្ទុកបុគ្គលិក</u> ត្រូវបានគ្រោងប្រមាណ ៨,៥ ទ្រីលានរៀល មានសមាមាត្រស្មើនឹង ៤៧,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៧,១៧% នៃ ផសស, មានកំណើន ៨,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ។ ចំណាយបន្ទុកបុគ្គលិក ត្រូវបានគ្រោងសម្រាប់៖ (១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ៧,០% ដោយដំឡើងបៀវត្សមូលដ្ឋានតាមតម្លៃឯកតាសន្ទស្សន៍ ២ ៥០០ រៀល ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ ២០២០ និង (២)-ការដំឡើងប្រាក់បំណាច់មុខងារបន្ថែមចំនួន ៣០ ០០០ រៀល ដល់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានប្រាក់បំណាច់មុខងារក្រោម ៩៦ ម៉ឺនរៀល, និង ២ ម៉ឺនរៀល ជូនមន្ត្រីដែលមានប្រាក់បំណាច់មុខងារចាប់ពី ៩៦ ម៉ឺន ១០០ រៀល ដល់ ១ លាន ១១ ម៉ឺនរៀល ដោយនឹងត្រូវអនុវត្តចាប់ពីខែ មេសា ដល់ ខែ ធ្នូ ឆ្នាំ ២០២០ ។ ខ្ញុំបាទគោរពស្នើសុំសមាជិក-សមាជិកានៃអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាយោងទៅសេចក្តីថ្លែងហេតុពិស្តារ ដើម្បីបានជ្រាបលម្អិតអំពីការផ្លាស់ប្តូរនៃស្ថានភាពបៀវត្សអប្បបរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ នៅក្នុងឆ្នាំ ២០២០ តាមរយៈវិធានការនេះ ។

ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលបានគ្រោងថវិកាដោយឡែកមួយចំនួនផ្សេងទៀត រួមមាន៖

- ថវិកាចំនួន ៤០ ប៊ីលានរៀល សម្រាប់ផ្តល់លទ្ធភាពដល់ក្រសួង-ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាព និង ជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ;
- ថវិកាចំនួន ៥០ ប៊ីលានរៀល ជាមូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីត-មន្ត្រីរាជការ និង អតីតយុទ្ធជន ដើម្បីរ៉ាប់រងលើការទ្រទ្រង់ថែទាំសុខភាពមន្ត្រី-សាធារណៈ;
- ថវិកាចំនួន ៦ ប៊ីលានរៀល ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យ-ការងារសម្រាប់មន្ត្រីសាធារណៈ ។

ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន ៦០ ប៊ីលានរៀល សម្រាប់ការ-ដំឡើងរបបសោធនប្រចាំខែទាបបំផុត និង កាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជន រវាងអ្នកទទួលបានសោធនទាប និង អ្នកទទួលបានសោធនខ្ពស់, និង រវាង និវត្តជនថ្មី និង និវត្តជនចាស់ ។

លើសពីនេះ, ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យាក៏នឹងត្រូវបានដំឡើងពីចំនួន ៦៥ ម៉ឺនរៀល នៅ ឆ្នាំ ២០១៩ ដល់ចំនួន ៦៧ ម៉ឺនរៀល នៅឆ្នាំ ២០២០ ផងដែរ ។

ក.១.២-<u>ចំណាយក្រៅបន្ទុកបុគ្គលិក</u> : មានកំណើន ៥,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ត្រូវជា ៧,៩៨% នៃ ផសស, និង មានសមាមាត្រស្មើនឹង ៥២,៧% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ។

### ក.២- អំពីទិដ្ឋភាពនៃការបែងចែកចំណាយចរន្តថវិកាថ្នាក់ជាតិតាមវិស័យ

ជារួម, ចំណាយចរន្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ ២០២០ ត្រូវបានវិភាជន៍ដោយផ្អែកលើតម្រូវការ និង អាទិភាពចាំបាច់ រួមទាំងការអនុវត្តនូវកម្មវិធីថ្មីមួយចំនួន ទៅតាមវិស័យធំៗទាំង ៤ រួមមាន ៖ វិស័យសង្គមកិច្ច, វិស័យការពារជាតិ និង សណ្តាប់ធ្នាប់សាធារណៈ, វិស័យរដ្ឋបាលទូទៅ, និង វិស័យសេដ្ឋកិច្ច, ហើយដែលអាទិភាពចំណាយសំខាន់ៗតាមវិស័យនីមួយៗ ក៏មានគូសបញ្ជាក់ពិស្តារនៅក្នុងខ្លឹមសារនៃអត្ថបទសេចក្តីថ្លែងហេតុនៃសេចក្តីព្រាង-ច្បាប់រួចហើយដែរ។ ដូច្នេះ, ដើម្បីចំណេញពេលបានថែមទៀត, ខ្ញុំបាទសូមមិនអធិប្បាយលម្អិតឡើងវិញទេ, ក៏ប៉ុន្តែ សូមធ្វើការគូសរំលេចដោយខ្លីថា **វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់ទុកជា វិស័យអាទិភាពទី ១** ដោយក្នុងនោះ ការយកចិត្តទុកដាក់ត្រូវបានផ្តោតជាពិសេសលើក្រសួងអាទិភាពចំនួន ៣ គឺ ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងការងារ និង បណ្តុះ-បណ្តាលវិជ្ជាជីវៈ និង ក្រសួងសុខាភិបាល, ព្រមទាំងផ្តោតទៅលើការឆ្លើយតបឱ្យបានសមស្របទៅនឹងអាទិភាព និង គោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលផ្នែកគាំពារសង្គមរួមមានជាអាទិ៍ ៖

(១)-*របបថែទាំសុខភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន ១០ ប៊ីលានរៀលសម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិកបេឡារបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាព ដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ ។

(២)-*របបឧបត្ថម្ភមាតុភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន ៤០ ប៊ីលានរៀលសម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយពេលសម្រាលកូនរួច តាមការកំណត់របស់រាជរដ្ឋាភិបាល ។

(៣)-*ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា* ៖ បានគ្រោងថវិកាចំនួន ៤០ ប៊ីលានរៀលសម្រាប់បង្កើន «**មូលនិធិគន្ធបុប្ផាកម្ពុជា**», ព្រមគ្នាជាមួយនឹងការបន្តផ្តល់ថវិកាចំនួន ៤១ ៣១៥ លានរៀល ជូនទៅមន្ទីរពេទ្យគន្ធបុប្ផាដោយផ្ទាល់សម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០២០, ដើម្បីធានានិរន្តភាព, គុណភាព និងប្រសិទ្ធភាពរបស់មន្ទីរពេទ្យ និង ធានាការផ្តល់សេវាដោយមិនយកថ្លៃ ជូនដល់កុមារនៃគ្រួសារក្រីក្រ ។ ការឧបត្ថម្ភនេះ មិនទាន់គិតបញ្ចូលនូវចំណូល ២ ដុល្លារអាមេរិក ពីទេសចរបរទេសម្នាក់ ពីការលក់សំបុត្រចូលទស្សនាប្រាង្គប្រាសាទក្នុងតំបន់អង្គរ ដែលរាជរដ្ឋាភិបាលបានសម្រេចកាត់យកបង់ដោយត្រង់ទៅជូន **មូលនិធិគន្ធបុប្ផាកម្ពុជា** សម្រាប់ផ្ទេរបន្តជូនទៅមន្ទីរពេទ្យគន្ធបុប្ផា នោះឡើយ ។

(៤)-*កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និង កុមារតូច រហូតដល់អាយុ ២ ឆ្នាំ* ៖ បានត្រៀមថវិកាចំនួន ៣០ ប៊ីលានរៀល ផងដែរ ។

**ចំពោះវិស័យសេដ្ឋកិច្ចវិញ** ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា ចំណាយចរន្តថ្នាក់ជាតិនៃវិស័យនេះនៅមានទំហំតូច ហើយក៏មិនបានទទួលនូវកំណើនច្រើននោះដែរ ក៏ប៉ុន្តែក្រសួងសំខាន់ៗនៃវិស័យនេះ ដូចជា ៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ, ក្រសួងធនធានទឹក និង ឧតុនិយម, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងសាធារណការ និង ដឹកជញ្ជូន ជាដើម, គឺជាស្ថាប័នដែលស្រូបយកចំណាយវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសរហូតដល់ជាង ៧០% សម្រាប់គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមាន ផ្លូវថ្នល់, ស្ពាន, លូ, ប្រព័ន្ធធារាសាស្ត្រ និង គម្រោងជំរុញផលិតកម្មស្បៀង ក៏ដូចជា ការកសាង និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធកសិកម្ម ។ល។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

### ខ.១- គម្រោងចំណាយមូលធន

ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោងចំនួន ប្រមាណ ១៣ ទ្រីលានរៀល, សមមូលនឹងប្រមាណ ៣,២ ប៊ីលានដុល្លារអាមេរិក, មានកំណើន ៤៦,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, មានសមាមាត្រស្មើនឹង ៤២,០% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១០,៩៧% នៃ ផសស, ដែលក្នុងនោះ ៖

(១)-**គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** *មានកំណើន ១៧០,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៩, មានទំហំប្រមាណ ៤,២២% នៃ ផសស ។ ការកើនឡើងនេះ គឺដោយសារការគ្រោងសំដៅដោះស្រាយផលប៉ះពាល់ពីភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន ដើម្បីជានាកំណើនសេដ្ឋកិច្ច, ភាពប្រកួតប្រជែងកម្ពុជា និង បង្កើតការងារបន្ថែមជូនប្រជាពលរដ្ឋ តាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ផ្សំចម្រុះ ដូចបានជម្រាបជូននៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុ ។*

(២)-**គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស** *មានកំណើនត្រឹម ១៣,៧% ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០១៩, មានទំហំប្រមាណ ៥,០៩% នៃ ផសស ដែលស្មើនឹងប្រមាណ ១៨% នៃចំណាយថវិការដ្ឋសរុបឆ្នាំ ២០២០ ។*

### ខ.២- ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២០

បន្ថែមលើអ្វីដែល **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** បានជម្រាបជូនអំបាញ់មិញ, ខ្ញុំសូមគូសបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលបានកំណត់ពិដានក្នុងការខ្ចីក្នុងកម្រិត ១ ៤០០ លានអេសដេអ៊ែរ ដែលស្មើនឹងឆ្នាំ ២០១៩ ដែរ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និង មានទំហំកាន់តែធំឡើងៗសម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគ

សាធារណៈ ដែលចេះតែរំកិលពីឆ្នាំមុនៗមក ហើយត្រូវរង់ចាំការចុះហត្ថលេខាដូចបានរំលេច ក្នុងខ្លឹមសារ នៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ ។ គម្រោងទាំងនេះសុទ្ធតែមាន ចរិតយុទ្ធសាស្ត្រ ក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និង វែង ជាពិសេស សម្រាប់ការសម្រេចបាននូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាង តិច ១% ក្នុងមួយឆ្នាំ ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទសូមគូសបញ្ជាក់ថា, ជារួម, ការបង្កើន ទំហំនៃការខ្ចីនេះនឹងមិនបង្កើតជាបន្ទុកបំណុលវណ្ឌកដល់កម្ពុជានោះទេ ព្រោះថានៅពេល ដែលសេដ្ឋកិច្ចមានការរីកចម្រើន នោះសមត្ថភាពសងរបស់កម្ពុជាក៏កើនខ្ពស់ជាងមុនដែរ ។ ជាក់ស្តែង, លទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្ទត់នៃការខ្ចីថ្មី បន្ថែមសម្រាប់ឆ្នាំ ២០២០ ដូចបានគូសបញ្ជាក់ខាងលើ បានបង្ហាញឱ្យឃើញថា អនុបាត បំណុលគន្លឹះទាំង ៤ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ដែលជាប្រការ បញ្ជាក់ថា ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមានចីរភាព និង មានហានិភ័យ កម្រិតទាប នៅក្នុងរយៈពេលមធ្យមដដែល ។

## VI- អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០២០

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មាន ឱនភាពថវិកាចំនួនប្រមាណ ១,១ ទ្រីលានរៀល ដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ ជាតិ ។ ធៀបនឹងច្បាប់ឆ្នាំ ២០១៩, ការឧបត្ថម្ភនេះមានកំណើន ៣៥,៧%, ត្រូវជា ០,៩១% នៃ ផសស ដែលត្រូវបានបែងចែកលម្អិតជូនទៅថ្នាក់រដ្ឋបាលនីមួយៗ ព្រមជាមួយនឹងការផ្តល់ អាទិភាពដល់ការដំឡើងប្រាក់ឧបត្ថម្ភជូនដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ និង មន្ត្រីភូមិ ដូចមាន គូសរំលេចពិស្តារនៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុ ។ ទន្ទឹមនេះ, ទិដ្ឋភាពថ្មីដែលគួរ កត់សម្គាល់ គឺការបង្កើតមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ ដែលត្រូវចាប់អនុវត្តចាប់ពីឆ្នាំ ២០២០ តទៅ ដោយរដ្ឋបាលឃុំ-សង្កាត់ទទួលបានការផ្ទេរធនធានបន្ថែមពីថវិការដ្ឋ ចំនួន ១% នៃ ចំណូលចរន្តថ្នាក់ជាតិ ក្នុង ១ ឆ្នាំ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានផ្ទាល់ សម្រាប់ឆ្នាំ ២០២០ ដល់ ឆ្នាំ ២០២៣ ។ ការឧបត្ថម្ភធនបន្ថែមនេះ, គួបផ្សំនឹងការផ្ទេរបន្ថែមនូវធនធាន ចំណូលមួយចំនួនពីរដ្ឋបាលថ្នាក់រាជធានី-ខេត្ត, នឹងធ្វើឱ្យទំហំមូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ នីមួយៗ កើនឡើងទ្វេដង នៅឆ្នាំ ២០២០, ពីប្រមាណ ១៤២ លានរៀល ឬ សមមូលនឹង ៣៥ ០០០ ដុល្លារអាមេរិក ជាមធ្យម ក្នុង ១ ឆ្នាំ, ទៅប្រមាណ ២៨៤ លានរៀល ឬ សមមូលនឹង ប្រមាណជាង ៧០ ០០០ ដុល្លារអាមេរិក ជាមធ្យមក្នុង ១ ឆ្នាំ ។

ជាមួយគ្នានេះ, គួរកត់សម្គាល់ថា ចំណាយថវិកាថ្នាក់ក្រោមជាតិ ត្រូវបានបង្កើនជាង ៤ ដង ធៀបនឹងឆ្នាំ ២០១៣ គឺពីប្រមាណ ៧៦៦ ប៊ីលានរៀល នៅឆ្នាំ ២០១៣ ឬ សមមូលនឹង ប្រមាណ ១៩០ លានដុល្លារអាមេរិក ដែលមានសមាមាត្រស្មើនឹង ៦,១% នៃចំណាយថវិកា

រដ្ឋសរុប, ហើយត្រូវជា ១,២៥% នៃ ផសស, ទៅដល់ប្រមាណ ៣,៣ ទ្រីលានរៀល នៅឆ្នាំ ២០២០ ឬ សមមូលនឹងប្រមាណ ៨២១ លានដុល្លារអាមេរិក ដែលមានសមាមាត្រស្មើនឹង ១០,០% នៃចំណាយថវិការដ្ឋសរុប, ហើយត្រូវជា ២,៨០% នៃ ផសស ។

## VII- អំពីតុល្យភាពរួមនៃថវិកាឆ្នាំ ២០២០

នៅក្នុងក្របខ័ណ្ឌ**<u>ថវិការដ្ឋ</u>** ឬ **<u>ថវិកាជាតិ</u>**ខាងលើ, ទាំងថវិកា**<u>ថ្នាក់ជាតិ</u>** និង ថវិកា**<u>ថ្នាក់ក្រោមជាតិ</u>**, រាជរដ្ឋាភិបាលអាចរក្សាអតិរេកថវិកាចរន្តឱ្យបានក្នុងកម្រិតប្រមាណ ៥,៣១% នៃ ផសស នៅឆ្នាំ ២០២០ ធៀបនឹងច្បាប់ឆ្នាំ ២០១៩ ដែលមានត្រឹម ២,៨៤% នៃ ផសស ។ ជាលទ្ធផល, **ឱនភាពថវិកាជាតិសរុប** នឹងមានទំហំស្មើនឹង **-៥,៨៨% នៃ ផសស** គឺកើនឡើងពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៩ ដែលស្មើនឹង -៥,៥១% នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញតុល្យភាពដោយហិរញ្ញប្បទានក្រៅប្រទេស ក្នុងទំហំ ៥,០៩% នៃ ផសស, មូលនិធិទ្រទ្រង់ថវិកាប្រមាណជា ០,២១% នៃ ផសស និង **ប្រាក់បញ្ញើរាជរដ្ឋាភិបាលក្នុងទំហំ ០,៥៩% នៃ ផសស ស្មើនឹង ៧០០ ប៊ីលានរៀល ឬ សមមូលនឹង ១៧៣ លានដុល្លារអាមេរិក** ដើម្បីអនុវត្តគោលនយោបាយវិត្តារកម្មថវិការបស់រាជរដ្ឋាភិបាល ។

## VIII- អំពីបញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០២០

ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើនេះ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំដម្នះបញ្ហាប្រឈម និង ហានិភ័យនានា, ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និង ទិដ្ឋភាពថវិកា, ប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ។ ក្នុងន័យនេះ, វិធានការដាក់លាក់សម្រាប់ឆ្នាំ ២០២០ ត្រូវបានដាក់ចេញ ដូចមានចែងក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ថវិកានេះដែលពាក់ព័ន្ធនឹង ៖ (១)-វិធានការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានពីហានិភ័យខាងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជា ផលប៉ះពាល់ពីភាពមិនច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាមួយដៃគូមួយចំនួន; (២)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណូល; (៣)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណាយ, ទាំងផ្នែករៀបចំ និង ផ្នែកអនុវត្តថវិកា; និង (៤)-ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ រួមមាន៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ៣ ជាពិសេស ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ និង យុទ្ធសាស្ត្រពាក់ព័ន្ធ, ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ, ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## IX - អំពីបទប្បញ្ញត្តិស្ដីពីពន្ធដារ

ក្នុងគោលបំណងផ្ដល់ភាពងាយស្រួល និងជួយសម្រាលបន្ទុកអ្នកជាប់ពន្ធ ឬសហគ្រាសនានា ព្រមទាំងដើម្បីជួយសម្រួលបន្ទុកជីវភាពរស់នៅរបស់មន្ត្រីរាជការ កម្មករ-និយោជិត និង ក្នុងស្មារតីធានានូវសង្គតិភាពនៃច្បាប់ និង បទប្បញ្ញត្តិស្ដីពីពន្ធដារ ក៏ដូចជាដើម្បីធានានូវភាពប្រកួតប្រជែង និង ការទាក់ទាញការវិនិយោគ និង ក្នុងគោលដៅជួយផ្ដល់លទ្ធភាពដល់រដ្ឋបាលរាជធានី-ខេត្ត ឱ្យមានធនធានកាន់តែច្រើនថែមទៀតក្នុងការអនុវត្តបេសកកម្ម និង ភារកិច្ចរបស់ខ្លួននៅមូលដ្ឋាន, រាជរដ្ឋាភិបាលស្នើដាក់ចេញនូវវិធានការដូចខាងក្រោម៖

**ទី១. ធ្វើវិសោធនកម្មមាត្រា ៤៧ ថ្មី(ពីរ) នៃច្បាប់ស្ដីពីសារពើពន្ធ ដើម្បីដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សជាប់ពន្ធ ឱ្យឡើងដល់ ១ ៣០០ ០០០ រៀល តាមរយៈអនុក្រឹត្យរបស់រាជរដ្ឋាភិបាល** ដើម្បីផ្ដល់ការលើកទឹកចិត្ត និង ក្នុងស្មារតីជួយសម្រួលបន្ទុកជីវភាពមួយកម្រិតថែមទៀត សម្រាប់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធ ជាពិសេសគ្រូបង្រៀន និង គ្រូពេទ្យ ព្រមទាំងកម្មករ-និយោជិត ដែលមានប្រាក់បៀវត្សទាប នៅក្នុងបរិការណ៍នៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការ ឱ្យបានកាន់តែខ្ពស់ជាង ១ លានរៀល ក្នុងមួយខែ នៅឆ្នាំ ២០២០ និង ការអនុវត្តគោលនយោបាយដំឡើងប្រាក់ឈ្នួលអប្បបរមាជូនដល់កម្មករ-និយោជិត ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ និង ផលិតស្បែកជើង ជារៀងរាល់ឆ្នាំ ហើយដែលប្រាក់ឈ្នួលអប្បបរមានេះនឹងកើនឡើងដល់ចំនួន ១៩០ ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០២០ ។ គួរបញ្ជាក់ដែរថា រាជរដ្ឋាភិបាលបានរៀបចំកែសម្រួលដំឡើងកម្រិតអប្បបរមានៃប្រាក់បៀវត្សត្រូវជាប់ពន្ធ ដែលមានចែងក្នុងមាត្រា ៤៧ នៃច្បាប់ស្ដីពីសារពើពន្ធជាបន្តបន្ទាប់ សរុបចំនួន ៣ លើករួចហើយ៖ **លើកទី ១** ពី ៥០ ម៉ឺនរៀល ដល់ ៨០ ម៉ឺនរៀល នៅឆ្នាំ ២០១៥, **លើកទី ២** ពី ៨០ ម៉ឺនរៀល ដល់ ១ លានរៀល នៅឆ្នាំ ២០១៧, និង **លើកទី ៣** ពី ១ លានរៀល ដល់ មួយលានពីរសែនរៀល នៅឆ្នាំ ២០១៨ ។ **ជារួម, ការកែសម្រួលកម្រិតអប្បបរមានៃប្រាក់បៀវត្សដែលត្រូវជាប់ពន្ធនេះនឹងបានជាគុណប្រយោជន៍ដល់ប្រជាពលរដ្ឋដ៏ច្រើនកុះករ, ទាំងសម្រាប់មន្ត្រីរាជការ, កម្មករ-និយោជិតទូទៅ, ក៏ដូចជា ចូលរួមចំណែកលើកកម្ពស់គុណភាពសេវាអប់រំ និង សុខាភិបាលផងដែរ ។**

**ទី២. ធ្វើវិសោធនកម្មមាត្រា ២០ ថ្មី(មួយ) នៃច្បាប់ស្ដីពីសារពើពន្ធ** ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងការអនុវត្តពន្ធលើប្រាក់បៀវត្ស និង ដើម្បីធានានូវសមធម៌រវាងនិយោជិតដែលទទួលប្រាក់បៀវត្សក្នុងក្របខណ្ឌបំពេញសកម្មភាពការងារ និង រូបវន្តបុគ្គលដែលទទួលចំណូលពីសកម្មភាពអាជីវកម្ម ។ ភាគនៃប្រាក់ចំណូលជាប់ពន្ធដែលសម្រេចបានដោយរូបវន្ត-បុគ្គល, សហគ្រាសឯកបុគ្គល, និង ចំណែកដែលត្រូវបែងចែកឱ្យសមាជិកម្នាក់ៗរបស់ក្រុមហ៊ុន

សហកម្មសិទ្ធិ ដែលមិនត្រូវបានចាត់ទុកជានីតិបុគ្គល ត្រូវធ្វើការកែសម្រួលឱ្យបានប្រហាក់ប្រហែលនឹង ១២ ដង នៃភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ ដែលនឹងត្រូវកំណត់ដោយអនុក្រឹត្យដូចពន្ធលើប្រាក់បៀវត្សដែរ ។

**ទី៣. ធ្វើវិសោធនកម្មមាត្រា២៣ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ទៅជាមាត្រា ២៣ថ្មី (ពីរ)** ដើម្បីឱ្យស្របទៅនឹងការវិវត្តសេដ្ឋកិច្ច-សង្គម និងស្របទៅនឹងការអនុវត្តល្អជាអន្តរជាតិ សំដៅកែលម្អថែមទៀតនូវបរិយាកាសវិនិយោគ និងធុរកិច្ច លើកកម្ពស់ភាព-ប្រកួតប្រជែង និងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ជាពិសេស តាមរយៈគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

**ទី៤. ធ្វើវិសោធនកម្មមាត្រា ៩ ថ្មី, មាត្រា ២២ ថ្មី, មាត្រា ៣១ ថ្មី, មាត្រា ៣២, មាត្រា ៣៧ ថ្មី, និង មាត្រា ៥៣ នៃច្បាប់ស្តីពីសារពើពន្ធ ដោយកែសម្រួល ឬ លុបវាក្យស័ព្ទមួយចំនួន** ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងការធ្វើវិសោធនកម្មមាត្រា ២៣ថ្មី(មួយ) ខាងលើ។

**ទី៥. ធ្វើវិសោធនកម្មមាត្រា ១៣១ និង មាត្រា ១៣២ នៃច្បាប់ស្តីពីសារពើពន្ធ** ដើម្បីផ្តល់ការអនុគ្រោះបន្ថយអត្រាការប្រាក់យឺតយ៉ាវក្នុងការបង់ប្រាក់ពន្ធពីចំនួន ២% ទៅ ១,៥% សំដៅជួយសម្រាលបន្ទុកអ្នកជាប់ពន្ធ ឬ សហគ្រាសនានា ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ទី៦. ធ្វើវិសោធនកម្មមាត្រា ៤៦, មាត្រា ៤៧, មាត្រា ៤៨, និង មាត្រា ៤៩ ស្តីពីពន្ធតែមប្រើសារពើពន្ធ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤** ដើម្បីឱ្យមានសង្គតិភាពជាមួយបទប្បញ្ញត្តិស្តីពីពន្ធតែមប្រើសារពើពន្ធ ដែលរាជរដ្ឋាភិបាលបានដាក់ចេញកន្លងមក ក៏ដូចជាជំរុញការអនុវត្តប្រមូលពន្ធនេះឱ្យមានប្រសិទ្ធភាពខ្ពស់ តាមរយៈការបង្កើនកិច្ចសហការក្នុងចំណោមអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និង ការផ្ទេរប្រភេទចំណូលពន្ធនេះទៅជូនរដ្ឋបាលរាជធានី-ខេត្ត ។

## X- អំពីនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

តាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលស្នើធ្វើនិយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការចំណាយថវិកាបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ចំនួន ១ ៩២៥ ១៩៨ លានរៀល ដើម្បីគោលដៅដូចខាងក្រោម៖

***ទី១.*** ផ្តល់ជូនធនាគារអភិវឌ្ឍន៍ជនបទចំនួន ២០៤ ២០០ លានរៀល សម្រាប់ទូទាត់ចំណាយបំពេញតម្រូវការឥណទានរបស់រោងម៉ាស៊ីនកិនស្រូវ ដើម្បីប្រមូលទិញស្រូវពី

ប្រជាកសិករនៅរដូវប្រមូលផលចុងឆ្នាំ ២០១៨ និង ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវបង្កើនដើមទុន ក្នុងការស្នើសុំអាជ្ញាបណ្ណធ្វើជាធនាគារពាណិជ្ជ ។

*ទី២.* ផ្តល់ជូនរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន ៩៩០ ៩៩៨ លានរៀល ក្នុងនោះ (១)-ឧបត្ថម្ភធនពីមូលនិធិអភិវឌ្ឍន៍របស់រដ្ឋបាលរាជធានីខេត្ត ចំនួន ៣៩២ ៩៥០ លានរៀល ដើម្បីបែងចែកទៅជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលរាជធានី-ខេត្ត, (២)-ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលក្រុងស្រុកចំនួន ១១ ៣៩៥ លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន, និង (៣)-ហិរញ្ញប្បទានពីអតិរេករបស់រដ្ឋបាលឃុំ-សង្កាត់ចំនួន ១៣៧ ២០៣ លានរៀល ដើម្បីប្រើប្រាស់សម្រាប់ហិរញ្ញប្បទានដល់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន។

*ទី៣.* ទូទាត់ចំណាយវិនិយោគលើការសាងសង់រោងចក្រផលិតអគ្គិសនី ៤០០ មេហ្គាវ៉ាត់ ចំនួន ១ ២៣០ ០០០ លានរៀល ដើម្បីជានាស្តេរភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ។

## XI- អំពីបទប្បញ្ញត្តិស្តីពីការធ្វើវិសោធនកម្មមាត្រា ៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលស្នើធ្វើវិសោធនកម្មមាត្រា ៤២ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការ-គ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស / រកម / ០៦១១ / ០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ដើម្បីធានានូវសង្គតិភាពនៃការអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅនឹងមាត្រា ៤ នៃច្បាប់នេះ ក៏ដូចជាដើម្បីផ្តល់នូវការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលខិតខំប្រមូលចំណូលបានលើសពីគម្រោងចំណូលប្រចាំឆ្នាំដែលបានអនុម័ត សម្រាប់ជាគុណប្រយោជន៍បម្រើឱ្យសេចក្តីត្រូវការជាក់ស្តែងនៃការអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន ។

## XII - សេចក្តីសន្និដ្ឋាន

សរុបមក, ការរៀបចំថវិកាឆ្នាំ ២០២០ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម និងហានិភ័យមួយចំនួនយ៉ាងណាក្តី, ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជដោយឈរលើគោលការណ៍ «**វិត្តារកម្មថវិកា**» សម្រាប់អនុវត្តអាទិភាពគោលនយោបាយសំខាន់ៗជាសារវ័ន្ត ដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស និង ការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ, **សូមសម្តេចអគ្គមហាពញាចក្រី** និង **អង្គសភាទាំងមូល** មេត្តាពិនិត្យ និង ផ្តល់ការអនុម័តលើ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០** ដោយអនុគ្រោះ ។

*សូមអរគុណ !*